ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែកញ្ញា ឆ្នាំ២០២២

នៅក្នុងខែកញ្ញា ឆ្នាំ២០២២នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា

-បានបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទី ចាប់ពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២។

១.១.១-បដិសណ្ឋារកិច្ចថ្នាក់ជាតិ-អន្តរជាតិ

-បានទទួលសារតាំងពីឯកឧត្តម Stenfan Anton Messerer ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពទើបតែងតាំងថ្មី នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។

-បានទទួលសារតាំងពីឯកឧត្តម Carlos Humberto Jiménez Licona ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពទើបតែងតាំងថ្មី នៃសាធារណរដ្ឋក្វាតេម៉ាឡា ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។

-បានទទួលសារតាំងពីឯកឧត្តម Uiadzimir Baravikou ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពទើបតែងតាំងថ្មី នៃសាធារណរដ្ឋបេឡារុស ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។

-បានអនុញ្ញាតឱ្យលោកជំទាវ UIKU Kocaefe ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋតួកគី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងសវនាការ នៅវិមានព្រឹទ្ធសភា។

-បានអនុញ្ញាតឱ្យគណៈប្រតិភូគណៈកម្មការស៊ើបអង្កេតអំពើពុករលួយ ការប្រព្រឹត្តខុស និងពង្រឹងអភិបាលកិច្ចល្អនៃព្រឹទ្ធសភា នៃព្រះរាជាណាចក្រថៃឡង់ដ៍ ដឹកនាំដោយឧត្តមនាវីឯក **សិសថាវ៉ាត វង្សសុវណ្ណ** ប្រធានគណៈកម្មការ ចូលជួបសម្តែងការគួរសម។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

១.១.២-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខ មន្ត្រី អាជ្ញាធរ កងកម្លាំងប៉ុស្តិ៍នគរបាល និងប្រជាពលរដ្ឋ នៅភូមិជើងឆ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ និងភូមិកណ្តាលកោះ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។

១.១.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញគោរពវិញ្ញាណក្ខន្ធព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ញឹម តេង** ដែលត្រូវជាម្តាយក្មេកលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅសង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

-បានអញ្ជើញគោរពព្រះវិញ្ញាណក្ខន្ធ ព្រះមហាក្សត្រិយ៍ **អេលីហ្សាបែតទី២** នៃចក្រភពអង់គ្លេស ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅស្ថានឯកអគ្គរាជទូតចក្រភពអង់គ្លេសក្នុងខណ្ឌដូនពេញ រាជធានីភ្នំពេញ។

-បានអញ្ជើញប្រារព្ធពិធីបង្សុកូល ឧទ្ទិសកុលសជូនដល់វិញ្ញាណក្ខន្ធ មហាឧបាសក **គង់ ខាត់** និងជូនដល់វិញ្ញាណក្ខន្ធ មាតា បិតា ញាតិការទាំង៧សន្តាន ដែលបានចែកឋានទៅកាន់លោកខាងមុខ នៅវត្តសុវណ្ណគិរី (ហៅវត្តជើងឆ្នុក) ស្ថិតនៅក្នុងភូមិជើងឆ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម។

-បានអញ្ជើញប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធ មាតា បិតា ញាតិការទាំង៧សន្តាន ដែលបានឋានទៅកាន់លោកខាងមុខ នៅភូមិកំណើតរបស់សម្តេច ភូមិកណ្តាលកោះ ស្ថិតក្នុងឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។

១.១.៤-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន១៣១ច្បាប់

-បានចុះហត្ថលេខាលើសំណើសុំព្រះរាជទានសិទ្ធិចំនួន១១៨ច្បាប់

-បានទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន១១៨ច្បាប់

-បានទទួលសំណើពីរដ្ឋសភាចំនួន៣ច្បាប់

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ ព្រឹទ្ធសភា**

-បានទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចាប់ពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២។

១.២.១-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញជាអធិបតីក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១៤ ស្ថិតនៅវត្តបទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចំនួន២លើក។

**១.២.២-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៤៥ច្បាប់។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

**១.៣.១-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធស្លាកសមិទ្ធផល លើការជួសជុលអគារក្រហម និងបណ្ណាល័យព្រឹទ្ធសភា ដែលជាជំនួយរបស់ស្ថានទូតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសាលបណ្ណាល័យព្រឹទ្ធសភា។

-បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាគោរពវិញ្ញាណក្ខន្ធសពព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ញឹម តេង** ម្តាយក្មេករបស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅសង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

-បានអញ្ជើញចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១១ នៃពិធីបុណ្យភ្ជុំបិណ្ឌ ដើម្បីឧទ្ទិសកុសលផលបុណ្យជូនដល់បុព្វការីជនដែលបានចែកឋានទៅលោកខាងមុខ នៅវត្តចំនួន០៤ ស្ថិតនៅឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ។

-បានអញ្ជើញចូលរួមក្នុងពិធីសូត្រមន្ត និងកាន់បិណ្ឌវេនទី១៤ នៃពិធីបុណ្យភ្ជុំបិណ្ឌ នៅវត្តបទុមវត្តី ស្ថិតក្នុងសង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**១.៣.២-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១០ច្បាប់។

## ២.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

## ២.១ មុខងារនីតិកម្ម

-បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំស្តីពីការបែងចែក និងប្រើប្រាស់ថវិកាឆ្នាំ២០២៣ របស់ព្រឹទ្ធសភា សម្រាប់រចនាសម្ព័ន្ធនយោបាយ រចនាសម្ព័ន្ធរដ្ឋបាល លទ្ធកម្ម និងការអភិវឌ្ឍន៍ នៅព្រឹទ្ធសភា

## ២.២ មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញជួបពិភាក្សា និងផ្លាស់ប្តូរបទពិសោធន៍ការងាររវាងគណៈប្រតិភូគណៈកម្មការស៊ើបអង្កេតអំពើពុករលួយ ការប្រព្រឹត្តខុស និងពង្រឹងអភិបាលកិច្ចល្អព្រឹទ្ធសភា នៃព្រះរាជាណាចក្រថៃឡង់ដ៍ ដឹកនាំដោយឧត្តមនាវីឯក **សិសថាវ៉ាត វង្សសុវណ្ណ** ប្រធានគណៈកម្មការ ក្នុងឱកាសដែលគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។

-បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខអាជ្ញាធរមានសមត្ថកិច្ចកំពុងប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន និងពិនិត្យស្ថានភាពចេញចូលរបស់ភ្ញៀវជាតិ-អន្តរជាតិ និងប្រជាពលរដ្ឋ នៅច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន នៃស្រុកគិរីវង់ ខេត្តតាកែវ។

## ២.៣ មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន១ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៣ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន៣ករណី កំពុងពិនិត្យសិក្សាចំនួន៣ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន៣ករណី ទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន៩ករណី។

-បានអញ្ជើញចូលរួមវេទិកាសាធារណៈ ជាមួយក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីស្តាប់ ទទួលសំណូមពរ និងរួមគ្នាដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ ដោយស្មារតីទទួលខុសត្រូវតាមភារកិច្ចរបស់ខ្លួន។

-បានអញ្ជើញចូលរួមវេទិកាភាពជាអ្នកដឹកនាំ និងភាពជាដៃគូអាស៊ានឆ្នាំ២០២២ ក្រោមប្រធានបទ " ភាពជាដៃគូសម្រាប់អាស៊ានដែលមានភាពស្អិតរមួត និងឆ្លើយតបរហ័ស" ក្រោមអធិបតីភាពសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានអាស៊ាន។

-បានអញ្ជើញជាអធិបតីក្នុងពិធីធ្វើបទបង្ហាញស្តីពី" បទពិសោធន៍ និងតួនាទីរបស់ព្រឹទ្ធសភា និងទស្សនវិស័យទាក់ទងនឹងឱកាសសម្រាប់ការចូលរួមរបស់សាធារណជន និងគណនេយ្យភាពក្នុងអំឡុងវដ្តថវិកា"។

-បានអញ្ជើញជាអធិបតីក្នុងពិធីប្រគល់ចង្ក្រានសន្សំសំចៃថាមពល ចំនួន២០០ចង្ក្រាន ជាអំណោយរបស់ក្រុមហ៊ុនGuangzhou Iceberg Environmental Consulting Services Co.Ltd តាមរយៈលោកបណ្ឌិត **ជា មុនីឫទ្ធិ** ប្រធានសមាគមស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន ជូនគ្រួសារកងទ័ព និងប្រជាពលរដ្ឋ ស្ថិតនៅភូមិដូនព្រៃង ឃុំព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។

-បានអញ្ជើញជាអធិបតីក្នុងពិធីប្រគល់ពានរង្វាន់បាល់ទាត់មិត្តភាពអាយុ៣៥ឆ្នាំឡើងចំនួន៤ខេត្ត រួមមាន៖ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប។

-បានអញ្ជើញនាំយកប្រភេទកូនឈើបេងអាហ្វ្រិក ចំនួន៥០០ដើម ដែលជាអំណោយឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជូនដល់អង្គភាពអគ្គបញ្ជាការដ្ឋានរថក្រោះ អគ្គបញ្ជាការប្រចាំទិសភូមិភាគទី៥ ស្ថិតនៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។

-បានអញ្ជើញចូលរួមពិធីសម្ពោធស្លាកសមិទ្ធផល លើការជួសជុលអគារក្រហម និងបណ្ណាល័យព្រឹទ្ធសភា ដែលជាជំនួយរបស់ស្ថានទូតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា និងឯកឧត្តម **វ៉ាង វិនធាន** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។

-បានអញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ ដើម្បីឈ្វេងយល់អំពីតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ការងារផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ បញ្ហាប្រឈម និងសំណូមពរ នៅខេត្តព្រៃវែង ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តត្បូងឃ្មុំ។

-បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខក្រុមប្រឹក្សាឃុំ ចំនួន៤៥នាក់ មកពីឃុំថ្កោវ ឃុំអូរស្វាយ និងឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដើម្បីឈ្វេងអំពីការផ្តល់សេវាជូនប្រជាពលរដ្ឋ ការធ្វើអត្តសញ្ញាណប័ណ្ណ

អត្រានុកូលដ្ឋាន ភូមិ-ឃុំមានសុវត្ថិភាព ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ និងបញ្ហាផ្សេងៗ។

-បានអញ្ជើញចូលរួមប្រជុំដើម្បីត្រៀមរៀបចំសិក្ខាសាលាស្តីពី "ស្វ័យភាពសេដ្ឋកិច្ចរបស់ស្ត្រីនៅតំបន់ជនបទ និងការចរចា និងសន្ទានកម្ម នៅក្នុងមជ្ឈដ្ឋានសភាប្រើភាសាបារាំង APF" នៅវិមានព្រឹទ្ធសភា។

-បានអញ្ជើញប្រជុំត្រៀមជួបសវនាការ ជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងក្រសួងកិច្ចការនារី និងករណីសំណើសុំរបស់តំណាងជនជាតិដើមភាគតិច១៦នាក់មកពី១៦អំបូរជនជាតិ ដើម្បីបង្ហាញ និងសុំពិគ្រោះយោបល់ផ្តល់ធាតុចូលក្នុងសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ និងច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២។

-បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ ចែកជូនដល់ក្រុមប្រឹក្សាឃុំ និងបងប្អូនប្រជាពលរដ្ឋក្នុងឃុំត្រពាំងវែង សរុបចំនួន៥០០នាក់ ស្ថិតនៅសាលាឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

-បានអញ្ជើញទទួលគណៈប្រតិភូដឹកនាំដោយ ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលោកស្រី **សុវណ្ណា** ប្រធានអង្គការសម្ព័ន្ធមិត្តសត្វព្រៃព្រមទាំងសហាការីចុះមកបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់នៅតំបន់អភិវឌ្ឍន៍ ម៉ុង ឫទ្ធីសែនជ័យ។

-បានអញ្ជើញចូលរួម និងនាំយកចង្ហាន់ ទេយ្យទាន គ្រឿងឧបភោគ បរិភោគ និងបច្ច័យទៅវេរប្រគេនព្រះសង្ឃនៅទីវត្តអារាម ក្នុងឱកាសបុណ្យកាន់បិណ្ឌ និងបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

-បានអញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗចំនួន៩៣លើក។

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរ

គ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំអាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនិងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅមូលដ្ឋានរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពង់ចាម ខេត្តពោធិ៍សាត់ ខេត្តកំពត ខេត្តកំពង់ស្ពឺ ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តស្ទឹងត្រែង ចំនួន៩៩លើក។

## ២.៤ កិច្ចសហប្រតិបត្តិការអន្តរជាតិ

ការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេស ទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្ម និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

-បានអញ្ជើញចូលរួមកិច្ចប្រជុំរបស់វេទិកាអាស៊ីប៉ាស៊ីហ្វិក លើកទី៦ (APPFGH6) ស្តីពីសុខភាពសកល ដែលរៀបចំដោយអង្គការសុខភាពពិភពលោក នៅទីក្រុងសេអ៊ូល នៃសាធារណរដ្ឋកូរ៉េ។

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការសង្គមកិច្ចសម្រាប់មហាសន្និបាតអន្តរសភាអាស៊ាន(AIPA) លើកទី៤៣ នៅវិមានរដ្ឋសភា។

-បានអញ្ជើញចូលរួមស្តាប់បទបង្ហាញរបស់លោកជំទាវ **Nguyen Tuong Van** អគ្គលេខាធិការអន្តរសភាអាស៊ាន (AIPA) ប្រចាំនៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី អំពីនីតិវិធី និងរបៀបរបបការងាររៀបចំមហាសន្និបាតអាយប៉ាលើកទី៤៣ ព្រមទាំងកិច្ចប្រជុំពាក់ព័ន្ធ នៅវិមានរដ្ឋសភា។

-បានអញ្ជើញចូលរួមប្រជុំតាមអនឡាញ Virtual Meeting រវាងរដ្ឋសភាកម្ពុជា ដឹកនាំ ដោយឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១ រដ្ឋសភា ជាមួយសមភាគីសភាប្រជាជនចិនទូទាំងប្រទេស ដឹកនាំដោយឯកឧត្តម **វ៉ាង ជិន** Wang Chen អនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ នៃសភាប្រជាជនចិនទូទាំងប្រទេស នៅរដ្ឋសភា។

-បានអញ្ជើញចូលរួមប្រជុំគណៈកម្មាធិការសេដ្ឋកិច្ច ដើម្បីពិនិត្យខ្លឹមសារលើសេចក្តី

ព្រាងសេចក្តីសម្រេច និងឯកសារទស្សនទាន និងកិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងអនុគណៈកម្មការ ខ្លឹមសារ និងឯកសារនៃគណៈកម្មាធិការរៀបចំមហាសន្និបាតអន្តរសភាអាស៊ាន AIPA លើកទី៤៣ នៅរដ្ឋសភា។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០២២

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

<u>ចម្លងជូន</u>

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ